ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
លេខ: ០១៣/ប្រ.ក...អ.ជ.ប.គ.ញ
០៩

# ប្រកាស
## ស្តីពី
## តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ
## នាយកដ្ឋាន ស្រាវជ្រាវ និង ត្រួតពិនិត្យ
## នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-បានឃើញអនុក្រឹត្យលេខ ១៣/អនក្រ/បក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-តាមសំណើររបស់អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សំរេច

**ប្រការ ១ :** ប្រកាសនេះ កំណត់តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យនៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ Phone / Fax: (855) 23 721 648 , 23 721 777. P.O. Box : 151
E-mail : info@nacd.gov.kh , Website : www.nacd.gov.kh

## អំពីតួនាទី និង ភារកិច្ច :

**ប្រការ ២ :** នាយកដ្ឋានស្រាវជ្រាវ និង ត្រួតពិនិត្យ មានតួនាទី និងភារកិច្ច ដូចតទៅ :

-ស្រាវជ្រាវ ក្តាប់សភាពការណ៍ ប្រមូលពត៌មានទូទៅ ដែលពាក់ព័ន្ធនឹងសារធាតុគីមី និង សារធាតុទាំងឡាយដែលប្រើប្រាស់សំរាប់ផ្សំគ្រឿងញៀន ព្រមទាំងសារធាតុដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងឱសថដែលមានសារធាតុញៀន សំដៅលើកវិធានការ គ្រប់គ្រង ត្រួតពិនិត្យ និងទប់ស្កាត់អោយមានប្រសិទ្ធភាព ។

-សហការ និងចូលរួមក្នុងកិច្ចប្រតិបត្តិការជាមួយក្រសួង និង អង្គភាពពាក់ព័ន្ធដ៏ទៃទៀត ក្នុងការតាមដាន និងត្រួតពិនិត្យ សារធាតុដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងសារធាតុគីមីសំរាប់ផលិតគ្រឿងញៀន និងឱសថដែលមានសារធាតុញៀន និងថ្នាំញៀនស្របច្បាប់កំណត់ដោយក្រសួងសុខាភិបាល ។

-សហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការត្រួតពិនិត្យ តាមដាន និងទប់ស្កាត់ការនាំចេញ នាំចូល ការចរាចរ ការប្រើប្រាស់ ការផលិត ការស្តុកទុកនូវសារធាតុគីមីផ្សំគ្រឿងញៀន និង សារធាតុដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ។

-សហការក្នុងការទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំ ពីជំនួញស្របច្បាប់ ទៅបំរើគោលដៅផលិតគ្រឿងញៀនខុសច្បាប់ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអង្គការដ៏ទៃទៀត ។

-រៀបចំឯកសារពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងសារធាតុគីមីផ្សំ សំរាប់បំពាក់បំប៉នដល់មន្ត្រីអនុវត្តច្បាប់ដែលមានការពាក់ព័ន្ធ និងបណ្តាសហគ្រាស ក្រុមហ៊ុន នាំចូលប្រើប្រាស់ ។

-អង្កេតស្រាវជ្រាវរកសារធាតុគីមីថ្មីៗ ដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទបន្ថែម ដើម្បីដាក់ចូលក្នុងតារាងត្រួតពិនិត្យ ។

**ប្រការ ៣ :** នាយកដ្ឋានស្រាវជ្រាវ និងត្រួតពិនិត្យ ដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋាន ០១ រូប និងមានអនុប្រធានជាជំនួយការ ។

-ប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើររបស់អគ្គលេខាធិការ ដោយមានការយល់ព្រមពីប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ពីក្នុងចំណោមមន្ត្រី ដែលមានឋានន្តរសក្តិវរៈមន្ត្រី នៃក្របខ័ណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិជាន់ខ្ពស់ចាប់ពីថ្នាក់ ឧត្តមសេនីយ៍ត្រី ។

-អនុប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើ ប្រធាននាយកដ្ឋានស្រាវជ្រាវ និង ត្រួតពិនិត្យ ដោយមានការឯកភាពពីអគ្គលេខាធិការក្នុងចំណោមមន្ត្រី ដែលមានឋានន្តរសក្តិអនុមន្ត្រី នៃក្របខ័ណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិជាន់ខ្ពស់ថ្នាក់វរ សេនីយ៍ឯក ។

**ប្រការ ៤** : ប្រធាននាយកដ្ឋានស្រាវជ្រាវ និង ត្រួតពិនិត្យ ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

-ទទួលខុសត្រូវលើការងារដំណើការ និង គ្រប់គ្រងនាយកដ្ឋាន និង ទទួលខុសត្រូវលើកិច្ចការនានា ចំពោះមុខអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-រាយការណ៍ជូនអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ពីកិច្ចការនានា ដែលទាក់ទងទៅនឹងការងារដំណើ ការ និងគ្រប់គ្រងនាយកដ្ឋាន។

-លើកសំណើអំពីការតែងតាំង ការតំឡើងឋានន្តរសក្តិ ឬ ផ្ទេរមន្ត្រីរាជការក្រោមឱវាទរបស់នាយកដ្ឋាន។

-ចុះហត្ថលេខាលើគ្រប់ឯកសារ ដែលទាក់ទងទៅនឹងការងាររបស់នាយកដ្ឋាន។

-មានសិទ្ធិ ធ្វើប្រតិភូកម្មអំណាចចុះហត្ថលេខា ដែលទាក់ទងកិច្ចការនាយកដ្ឋាន ដល់អនុប្រធាននាយកដ្ឋាន។

**ប្រការ ៥** : អនុប្រធាននាយកដ្ឋានស្រាវជ្រាវ និង ត្រួតពិនិត្យ ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

-ទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋាន ចំពោះកិច្ចការនានា ដែលប្រគល់អោយ

-ត្រូវរាយការណ៍ជូនប្រធាននាយកដ្ឋានអំពីកិច្ចការនានា ដែលស្ថិតក្រោមការទទួលខុសត្រូវ ឬ សមត្ថកិច្ចរបស់ខ្លួន។

-មានសិទ្ធិ ចុះហត្ថលេខាលើឯកសារដែលទាក់ទងនឹងកិច្ចការរដ្ឋបាល ក្រោមការធ្វើប្រតិភូកម្ម ពីប្រធាននាយកដ្ឋាន។

## អំពីរចនាសម្ព័ន្ធ :

**ប្រការ ៦** : នាយកដ្ឋានស្រាវជ្រាវ និង ត្រួតពិនិត្យ មាន ៥ ការិយាល័យ ជាសេនាធិការ :

**-ការិយាល័យរដ្ឋបាល សរុប**

**-ការិយាល័យស្រាវជ្រាវសារធាតុគីមី**

**-ការិយាល័យគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីវិស័យឧស្សាហកម្ម**

**-ការិយាល័យគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីផ្សំវិស័យសុខាភិបាល**

**-ការិយាល័យត្រួតពិនិត្យឱសថមានសារធាតុញៀន**

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន ០១ រូប អមដោយអនុប្រធានការិយាល័យយ៉ាងច្រើន ០៣ រូប ។ ប្រធានការិយាល័យត្រូវតែងតាំងដោយប្រកាសរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើរបស់ប្រធាននាយកដ្ឋានស្រាវជ្រាវ និង ត្រួតពិនិត្យ ដោយមានការឯកភាពពីអគ្គលេខាធិការ ពីក្នុងចំណោមមន្ត្រីដែលមានឋានន្តរសក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិថ្នាក់វរ សេនីយ៍ត្រី។

អនុប្រធានការិយាល័យ ត្រូវតែងតាំងដោយប្រកាស របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើរបស់ប្រធាននាយកដ្ឋានស្រាវជ្រាវ និង ត្រួតពិនិត្យ ដោយមានការឯកភាពពីអគ្គលេខាធិការ ពីក្នុងចំណោមមន្ត្រីដែលមានឋានន្តរសក្តិក្រមការដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ឬនាយនគរបាលជាតិថ្នាក់វរៈ សេនីយ៍ត្រី ។

អង្គការលេខរបស់នាយកដ្ឋានស្រាវជ្រាវ និង ត្រួតពិនិត្យមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ ។

## អំពីភារកិច្ចរបស់ការិយាល័យ

**ប្រការ ៧ : ការិយាល័យរដ្ឋបាល សរុប មានភារកិច្ច :**

-ទទួលសំណុំឯកសារចេញ-ចូល គ្រប់ស្ថាប័នពាក់ព័ន្ធនាយកដ្ឋាន ជុំវិញរបស់អគ្គលេខាធិការដ្ឋាន

-ទទួលរៀបចំទុកដាក់ឯកសារ ដែលពាក់ព័ន្ធ និង គ្រប់គ្រងឯកសារដែលមានក្នុងនាយកដ្ឋាន

-តាមដានការងារ វាយតំលៃក្នុងនាយកដ្ឋាន

-លើកផែនការ តាមដានផែនការ វាយតំលៃសន្និដ្ឋានទូវលទ្ធផលការងារជូននាយកដ្ឋាន

-សំរបសំរួលការងារទូទៅក្នុងនាយកដ្ឋាន

-សំរាប់ទំនាក់ទំនងការងារជាមួយអន្តរក្រសួងពីពត៌មានផ្សេងៗ ។

-ទំនាក់ទំនងស្ថាប័នពាក់ពន្ធ័ជាមួយអង្គការដែលជាដៃគូ និង អង្គការក្រៅរដ្ឋាភិបាល ។

-ទំនាក់ទំនង និង ទទួល បញ្ជូនពត៌មានទៅវិញទៅមកលើបណ្តាខេត្ត/ក្រុង និង BLO ។

-ប្រមូល និងគ្រប់គ្រងទិន្នន័យសារធាតុគីមី ការនាំចូល-ចេញ ក្នុងការប្រើប្រាស់របស់ឧស្សាហកម្មគីមី និងស្ថាប័នពាក់ពន្ធ័ ដើម្បីងាយស្រួលត្រួតពិនិត្យ និង តាមដាន ។

**ប្រការ ៨ : ការិយាល័យស្រាវជ្រាវសារធាតុគីមី មានភារកិច្ច :**

-កសាងប្រើប្រាស់បណ្តាញមូលដ្ឋានសំងាត់ ដើម្បីបំរើការងារតាមដានសភាពការណ៍សកម្មភាពរបស់ឈ្មួញជួញដូរគ្រឿងញៀន

-រៀបចំបញ្ជីដើម្បីតាមដាន ស្រាវជ្រាវរកមុខសញ្ញា ការទិញ លក់ដូរ ដឹកជញ្ជូន ផលិតផលសារធាតុគីមីផ្សំ

-ប្រមូលវត្ថុតាងឯកសារពាក់ព័ន្ធ ដើម្បីសុំការចោទប្រកាន់ពីព្រះរាជអាជ្ញាលើអ្នកលក់ ចែកចាយ ដឹកជញ្ជូន ទិញផលិតផលសារធាតុគីមីផ្សំ ដែលមិនមានច្បាប់អនុញ្ញាត

-ដំណើការស្រាវជ្រាវមូលដ្ឋាន និង ធ្វើការស៊ើបបញ្ជាក់ពត៌មាននានាទាក់ទងនឹងការដឹកជញ្ជូន ការចរាចរសារធាតុគីមីផ្សំ ដែលកំណត់ដោយក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ

-ទំនាក់ទំនងពត៌មានជាមួយអង្គភាពនានា ដែលពាក់ព័ន្ធជាមួយអង្គការជាតិ អន្តរជាតិ និងប្រទេសនានា ក្នុងតំបន់ដែលពាក់ព័ន្ធសារធាតុគីមីផ្សំ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ

-តាមដាន និងណែនាំ សហការជាមួយក្រុមលេខាធិការដ្ឋាន និងគណៈកម្មការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង អំពីវិធានការជំនាញពាក់ព័ន្ធនឹងការងារស្រាវជ្រាវ

-លើកយោបល់ជូនថ្នាក់ដឹកនាំនាយកដ្ឋាន ក្នុងការទំនាក់ទំនងសុំជំនួយបច្ចេកទេសដែលពាក់ព័ន្ធក្នុងការងារស្រាវជ្រាវ និងត្រួតពិនិត្យ

-សហការត្រួតពិនិត្យការនាំចូល នាំចេញ សារធាតុគីមីផ្សំ និងឱសថ ដែលកំណត់ដោយច្បាប់

-ត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំ របស់បណ្តាក្រុមហ៊ុន សហគ្រាសនានា ការលក់ដូរ ការចែកចាយ ការទិញ ការផលិតសារធាតុគីមីផ្សំ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ

-ក្តាប់តួលេខតំរូវការ បរិមាណប្រើប្រាស់សារធាតុគីមីផ្សំ ដើម្បីធ្វើការវាយតំលៃ និង ពិនិត្យពេលមានបាតុភាពមិនប្រក្រតី

-សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំបទដ្ឋាននានាក្នុងការតាមដាន គ្រប់គ្រង និង ត្រួតពិនិត្យសារធាតុគីមីផ្សំអោយមានប្រសិទ្ធភាព

-ការិយាល័យស្រាវជ្រាវសារធាតុគីមី ត្រូវគ្រប់គ្រង និង ទទួលខុសត្រូវដោយប្រធាន ការិយាល័យ ០១ រូប អនុប្រធានការិយាល័យជាច្រើនរូប និងមន្ត្រីជំនាញតាមការចាំបាច់ ។

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋានប្រគល់អោយ

**ប្រការ ៩ : ការិយាល័យគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីវិស័យឧស្សាហកម្ម មានភារកិច្ច :**

-សហការត្រួតពិនិត្យការនាំចូល នាំចេញ សារធាតុគីមីផ្សំ និងឱសថ ដែលកំណត់ដោយច្បាប់

-ត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំ និងឱសថ បណ្តាក្រុមហ៊ុន សហគ្រាស នានា

-ត្រួតពិនិត្យការលក់ដូរ ការចែកចាយ ការទិញ ការផលិតសារធាតុគីមីផ្សំ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ

-ក្តាប់តួលេខតំរូវការ បរិមាណប្រើប្រាស់សារធាតុគីមីផ្សំ ដើម្បីធ្វើការវាយតំលៃ និងត្រួតពិនិ ត្យពេលមានបាតុភាពមិនប្រក្រតី

-ធ្វើរបាយការណ៍ជូនទៅអគ្គលេខាធិការ តាមនាយកដ្ឋានពីសារធាតុគីមីផ្សំថ្មីៗ ដែលអាចបង្វែរយកទៅផលិតគ្រឿងញៀនបាន ដើម្បីដាក់បញ្ចូលសារធាតុនោះទៅក្នុងបញ្ជីការត្រួតពិនិត្យពិសេស

-សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំបទដ្ឋាននានាក្នុងការគ្រប់គ្រង និង ត្រួតពិនិត្យសារធាតុគីមីផ្សំ អោយមានប្រសិទ្ធភាព

-ការិយាល័យគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីវិស័យឧស្សាហកម្ម ត្រូវគ្រប់គ្រង និង ទទួលខុសត្រូវដោយប្រធានការិយាល័យ ០១ រូប អនុប្រធានការិយាល័យជាច្រើនរូប និងមន្ត្រីជំនាញតាមការចាំបាច់ ។

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋានប្រគល់អោយ

**ប្រការ ១០ ៖ ការិយាល័យគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីផ្សំវិស័យសុខាភិបាល មានភារៈកិច្ច ៖**

-ក្ដាប់សភាពការណ៍ និងផ្ដល់ពត៌មានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសពត៌មានដែលទាក់ទង នឹងសារធាតុគីមីផ្សំ ដែលបណ្ដាក្រុមហ៊ុនឧស្សាហកម្មគីមី និងក្រុមហ៊ុនវិនិយោគសុំការនាំចូល ការចែកចាយ ការលក់ដុំ-រាយ ការប្រើប្រាស់ ការស្តុកទុក និង សេចក្ដីត្រូវការជាក់ស្តែងតាមបណ្ដារោងចក្រ សហគ្រាស មូលដ្ឋានផលិតកម្ម និង សិប្បកម្មនានា

-ធ្វើការសំរបសំរួល និងរួមកិច្ចសហប្រតិបត្តិការជាមួយក្រសួង និង អង្គភាពដែលពាក់ព័ន្ធដ៏ទៃទៀតក្នុងការតាមដានត្រួតពិនិត្យជាមួយក្រុមការងារអន្តរក្រសួង និងគណៈកម្មការ អន្តរក្រសួងជាប្រចាំរាល់ការនាំចូល ការនាំចេញ ការចែកចាយ ការដឹកជញ្ជូន ការប្រើប្រាស់ នូវរាល់សារធាតុគីមីផ្សំតាមសង្វាក់ផលិតកម្មកំពុងប្រើប្រាស់ ។

-ត្រួតពិនិត្យនូវរាល់ឯកសារដែលទាក់ទងដល់ការស្នើសុំអាជ្ញាប័ណ្ណនាំចូលសារធាតុគីមីផ្សំគ្រប់ប្រភេទតាមបណ្ដារោងចក្រ-សហគ្រាស ដែលបានទទួលការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ច

-ការិយាល័យគ្រប់គ្រងត្រួតពិនិត្យសារធាតុគីមីផ្សំវិស័យសុខាភិបាល ត្រូវគ្រប់គ្រង និង ទទួលខុសត្រូវដោយប្រធានការិយាល័យ ០១ រូប អនុប្រធានការិយាល័យជាច្រើនរូប និងមន្ត្រីជំនាញតាមការចាំបាច់ ។

-អនុវត្តភារៈកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋានប្រគល់អោយ

**ប្រការ ១១ ៖ ការិយាល័យត្រួតពិនិត្យឱសថមានសារធាតុញៀន មានភារកិច្ច ៖**

-ផ្លាស់ប្ដូរ និងផ្ដល់ពត៌មានរវាងក្រសួងពាក់ព័ន្ធ ពិសេសពត៌មានដែលទាក់ទងដល់ការអនុញ្ញាតអោយនាំចូល ការនាំចូលជាក់ស្តែង ការចែកចាយ និងលក់ដុំ លក់រាយឱសថគ្រប់ប្រភេទ ដើម្បីក្ដាប់បានអំពីបរិមាណត្រូវការ ការស្តុកទុកតាមបណ្ដាក្រុមហ៊ុន រោងចក្រ និង មូលដ្ឋានផលិតកម្ម ពាណិជ្ជកម្មយកទៅផលិតឱសថស្របច្បាប់ និង ខុសច្បាប់

-លើកឡើងនូវវិធានការចាំបាច់ដើម្បីធានាការគ្រប់គ្រង ការធ្វើចរាចរ ចែកចាយឱសថគ្រប់ប្រភេទសារធាតុគីមីអាចយកផ្សំគ្រឿងញៀនបាន សំដៅទប់ស្កាត់បាននូវរាល់បាតុភាពការនាំចូល និងការក្លែងបន្លំឱសថសម័យ និង បុរាណ មិនស្របច្បាប់មកជាថ្នាំញៀនខុសច្បាប់

-ត្រួតពិនិត្យគ្រប់ប្រភេទថ្នាំចំរាញ់ចេញពីរុក្ខជាតិញៀន និងសារធាតុគីមីផ្សំ បញ្ចូលគ្នាទៅជាឱសថសម័យ-បុរាណខ្មែរ និង ថ្នាំចិនសែ ។ល។ ដែលស្តុកទុក ឬធ្វើចរាចរ ដាក់លក់តាមទីផ្សារសាធារណៈ

-ត្រួតពិនិត្យរាល់ឯកសារទាក់ទងដល់ការសុំអាជ្ញាប័ណ្ណនាំចូលឱសថ របស់បណ្ដាស្ថាប័ន រោងចក្រសហគ្រាស ដែលទទួលការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ច

-តាមដានការត្រួតពិនិត្យរាល់ផែនការផលិតឱសថរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស លើបទដ្ឋាន

បច្ចេកទេស ការស្តុកទុក ការចែកចាយវត្ថុធាតុដើម មានលក្ខណៈជាឱសថមានសារធាតុញៀន ដែលជាសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

-ផ្តល់យោបល់ទៅក្រសួងពាក់ព័ន្ធ

ដើម្បីចាត់វិធានការ ធានាបង្ការលើការបង្វែរឱសថមានសារធាតុញៀន ទៅផលិតគ្រឿងញៀន ដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

-ចុះត្រួតពិនិត្យ តាមដានការប្រើប្រាស់ ការលក់ដូរតាមឱសថស្ថាន-រង ទូទាំងប្រទេស

-ការិយាល័យត្រួតពិនិត្យឱសថមានសារធាតុញៀន ត្រូវគ្រប់គ្រង និង ទទួលខុសត្រូវដោយប្រធានការិយាល័យ ០១ រូប អនុប្រធានការិយាល័យជាច្រើនរូប និងមន្ត្រីជំនាញតាមការចាំបាច់។

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋានប្រគល់អោយ

**ប្រការ ១២ :** រាល់ប្រកាស ដីកា និងលិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៣ :** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន. អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន. អគ្គស្នងការនគរបាលជាតិ. អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ និងនគរបាល. អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភា និង ហិរញ្ញវត្ថុ. អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ. ប្រធានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង. ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី..១១.......ខែ.....មីនា........ឆ្នាំ២០០៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជា**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

ស ខេង

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-សមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

*(ដើម្បីជូនជ្រាប)* ។

-ដូចប្រការ ១៣ (ដើម្បីអនុវត្ត)

-ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធតួនាទី ភារកិច្ច នាយកដ្ឋានស្រាវជ្រាវ និង ត្រួតពិនិត្យ

- ប្រធាននាយកដ្ឋាន
  - អនុប្រធាននាយកដ្ឋាន
    - ការិយាល័យ រដ្ឋបាល សរុប
    - ការិយាល័យ ស្រាវជ្រាវសារធាតុគីមី
    - ការិយាល័យគ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមី វិស័យឧស្សាហកម្ម
    - ការិយាល័យគ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំ វិស័យសុខាភិបាល
    - ការិយាល័យ ត្រួតពិនិត្យឱសថ មានសារធាតុញៀន